ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា
## ថ្ងៃទី១៩-២០ ខែមិថុនា ឆ្នាំ២០០៧

## *សេចក្តីប្រកាសព័ត៌មាន*

## រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ឯកភាពលើការពង្រឹងនិងបង្កើនវឌ្ឍនភាពក្នុងការអនុវត្តន៍ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

***ភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៧*** **:** វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី១បានប្រារព្ធឡើង នៅរាជធានីភ្នំពេញ នាថ្ងៃទី១៩-២០ ខែមិថុនា ឆ្នាំ២០០៧ ។ វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ដែលបានជំនួសឱ្យកិច្ចប្រជុំពិគ្រោះយោបល់ ដែលធ្លាប់ត្រូវបានដឹកនាំរួមគ្នាដោយរាជរដ្ឋាភិបាល និងធនាគារពិភពលោក ជាវេទិកាដើម្បីពិភាក្សារួមគ្នាលើការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងជាការចង្អុលបង្ហាញពីការឈានទៅរកភាពដឹកនាំដ៏ពេញលេញរបស់រាជរដ្ឋាភិបាលទៅលើរបៀបវារៈអភិវឌ្ឍន៍ជាតិ ដោយរក្សាបាននិងពង្រឹងភាពជាដៃគូជាមួយនឹងសហគមន៍អន្តរជាតិ និងសង្គមស៊ីវិល ។ វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាផ្តល់នូវកាលានុវត្តភាព សម្រាប់កិច្ចពិភាក្សាកម្រិតខ្ពស់រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍អំពីវឌ្ឍនភាពក្នុងការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

កិច្ចប្រជុំបានឯកភាពថា ការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិក្នុងឆ្នាំដំបូង ទទួលបាននូវវឌ្ឍនភាពគួរឱ្យកត់សំគាល់ ដោយក្នុងនោះកំណើនសេដ្ឋកិច្ចសម្រេចបានប្រកបដោយចីរភាព និងមានការរីកចំរើនជឿនលឿនលើសូចនាករផ្នែកសង្គមកិច្ចផងដែរ ។ ប៉ុន្តែទន្ទឹមនឹងលទ្ធផលជាវិជ្ជមានទាំងនេះ វេទិកាក៏បានគូសបញ្ជាក់ពីភាពចាំបាច់ ត្រូវបន្តប្រឹងប្រែងបន្ថែមទៀតដើម្បីកាត់បន្ថយអត្រាស្លាប់របស់មាតា និងអត្រាសិស្សបោះបង់ការសិក្សា ។

ដោយសម្លឹងឆ្ពោះទៅអនាគត រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍បានឯកភាពគ្នាបន្តកិច្ចប្រឹងប្រែងជំរុញឱ្យមានវឌ្ឍនភាពបន្ថែមទៀតក្នុងវិស័យសង្គមកិច្ច និងបង្កើនល្បឿនការអនុវត្តន៍កំណែទម្រង់សំខាន់ៗ និងពង្រឹងអភិបាលកិច្ច ។

**************

«វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា លើកទី១» បានប្រព្រឹត្តទៅក្រោមកិច្ចដឹកនាំរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី **គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។ វេទិកាមានការចូលរួមពីតំណាងជាន់ខ្ពស់របស់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល និងគណៈប្រតិភូមកពីសហគមន៍ដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍ប្រមាណ២៥ប្រទេស និងស្ថាប័ន និងមានការចូលរួមពីតំណាងអង្គការសង្គមស៊ីវិលផងដែរ ។

មានមតិស្វាគមន៍ ឯកឧត្តម ទេសរដ្ឋមន្ត្រី **គាត ឈន់** បានមានប្រសាសន៍ថាឆ្នាំ ២០០៧ ជាឆ្នាំទី ៩ ហើយដែលកម្ពុជាបានរស់នៅក្នុងសុខសន្តិភាព និងស្ថេរភាពសង្គម និងសម្រេចបាននូវការអភិវឌ្ឍន៍សេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រគួរអោយកត់សំគាល់ ។ ប៉ុន្តែរាជរដ្ឋាភិបាលនៅមិនទាន់ពេញចិត្តនឹងលទ្ធផលជាផ្លែផ្កានេះនៅឡើយទេ និងនៅមានបញ្ហាប្រឈមជាច្រើនទៀតដែលត្រូវដោះស្រាយ «នោះគឺការកាត់បន្ថយភាពក្រីក្រតាមបាវចនា«សមធម៌»នៃយុទ្ធសាស្ត្រចតុកោណ» ព្រោះថាបើភាពក្រីក្រនៅបន្តអត្ថិភាពត្រាំត្រែងតទៅទៀតនោះ រាជរដ្ឋាភិបាលពិតជានឹងបាត់បង់នូវកាលានុវត្តភាពក្នុងការប្រើប្រាស់សក្តានុពលនៃធនធានសេដ្ឋកិច្ចនិងធនធានមនុស្សដ៏មានតម្លៃសម្រាប់ការអភិវឌ្ឍន៍ប្រទេស ។ ការកាត់បន្ថយភាពក្រីក្រនឹងមិនអាចសម្រេចទៅបានឡើយ ប្រសិនបើគ្មានការបន្តបង្កើនជាដុំកំភួននូវផលិតភាពដំណាំស្រូវ ការបន្តប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ការពន្លឿនល្បឿនកំណែទម្រង់គន្លឹះៗ និងការកៀរគរធនធានអោយបានសមស្របសម្រាប់អភិវឌ្ឍជាតិ ។

ថ្លែងនៅក្នុងសុន្ទរកថាគន្លឹះបើកវេទិកា សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាបានមានប្រសាសន៍ថាការផ្លាស់ប្តូរពីការប្រជុំពិគ្រោះយោបល់ មករៀបចំជាវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជានាពេលនេះ «គឺជាដំណើរការដែលឆ្លុះបញ្ចាំងឱ្យឃើញពីការងើបឈរកាន់តែរឹងមាំឡើងៗ បន្តិចម្តងៗ ក្នុងន័យនៃការកសាងសមត្ថភាព ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការងារអភិវឌ្ឍន៍របស់កម្ពុជាខ្លួនឯងផ្ទាល់» ។

សុន្ទរកថាគន្លឹះរបស់សម្តេចនាយករដ្ឋមន្ត្រីបានគូសបញ្ជាក់ពីភាពចាំបាច់ដែលត្រូវពន្លឿនល្បឿននៃការអនុវត្តន៍កំណែទម្រង់បន្ថែមទៀត ។ ជាការឆ្លើយតបនឹងកង្វល់ដែលសហគមន៍ដៃគូអភិវឌ្ឍន៍តែងតែ

លើកឡើងពាក់ព័ន្ធនឹងកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ សម្តេចនាយករដ្ឋមន្ត្រីបានគូសបញ្ជាក់ថា រាជរដ្ឋាភិបាល «នៅតែយល់ស្របជាមួយដៃគូអភិវឌ្ឍន៍របស់យើងដែរថា ច្បាប់ប្រឆាំងនឹងអំពើពុករលួយនេះ វាគឺជាសមាសធាតុគន្លឹះមិនអាចខ្វះបានមួយ សម្រាប់ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយប្រកបដោយប្រសិទ្ធភាព ។ ទន្ទឹមនឹងសេចក្តីត្រូវការដ៏ចាំបាច់ក្នុងការធានានូវសង្គតិភាពក្នុងការតាក់តែងច្បាប់ដែលមានការពាក់ព័ន្ធគ្នា រាជរដ្ឋាភិបាលនៅតែមានការប្តេជ្ញាចិត្តឥតរាថយ ក្នុងការជំរុញកសាងសេចក្តីព្រាងច្បាប់នេះ ឱ្យបានសម្រេចយ៉ាងឆាប់រហ័សតាមតែអាចធ្វើទៅបាន» ។

សុន្ទរកថាគន្លឹះរបស់សម្តេចនាយករដ្ឋមន្ត្រីក៏បានសង្កត់ធ្ងន់ពីអាទិភាពរបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព និងសមធម៌សម្រាប់គាំទ្រដល់កិច្ចអភិវឌ្ឍន៍ ។ អាទិភាពរបស់រាជរដ្ឋាភិបាលប្រមូលផ្តុំលើវិធានការពង្រឹងប្រព័ន្ធគ្រប់គ្រង បែងចែក និងប្រើប្រាស់ប្រកបដោយសមធម៌ និងធានាបាននូវប្រសិទ្ធភាពសេដ្ឋកិច្ច តាមរយៈការចុះបញ្ជីដីធ្លី ការបែងចែកដីធ្លី ការធានាសុវត្ថិភាពនៃកម្មសិទ្ធលើដីធ្លី និងការលុបបំបាត់ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដីដោយខុសច្បាប់ ។ ជាអនុសាសន៍ សម្តេចបានស្នើឱ្យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ «សូមមេត្តារួមគ្នាពិនិត្យ ដោយសហការអាជ្ញាធរដែនដីដែលមានការពាក់ព័ន្ធ ដើម្បីដកយកផ្ទៃដីមួយចំនួនដែលមានលក្ខណៈសមស្របពីក្នុងផ្ទៃដីសម្បទានសេដ្ឋកិច្ចដែលរាជរដ្ឋាភិបាលទើបតែបានដកហូតយកពីក្រុមហ៊ុនទាំង៥ នាពេលថ្មីៗកន្លងទៅនេះ យកមករៀបចំជាដីសម្បទានសង្គមកិច្ចសម្រាប់បែងចែកឱ្យបានឆាប់រហ័សជូនដល់ប្រជាពលរដ្ឋដែលគ្មានដីប្រើប្រាស់ពិតប្រាកដ» ។

លើបញ្ហាពាក់ព័ន្ធនឹងលទ្ធភាពនៃការអាចទទួលបានចំណូលបន្ថែមពីអាជីវកម្មប្រេង និងឧស្ម័ន សម្តេចនាយករដ្ឋមន្ត្រីបានគូសបញ្ជាក់ថា ផ្អែកលើជោគជ័យដែលរាជរដ្ឋាភិបាលសម្រេចបាននៅក្នុងកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលនឹងរៀបចំឱ្យបាននូវក្របខ័ណ្ឌគ្រប់ជ្រុងជ្រោយមួយដើម្បីបង្កើនផលចំណូលពីអាជីវកម្មវិស័យប្រេង និងឧស្ម័ន និងធានាឱ្យបានការប្រើប្រាស់ជាអតិបរមាដើម្បីជាគុណប្រយោជន៍សម្រាប់អភិវឌ្ឍកម្ពុជា ។

ជាមួយនេះផងដែរ វេទិកាបានគូសបញ្ជាក់ពីភាពចាំបាច់ក្នុងការភ្ជាប់ដំណើរការពិភាក្សាឡើងវិញនៅក្នុងកិច្ចប្រឹងប្រែងកែទម្រង់រដ្ឋបាលសាធារណៈ សំដៅរួមគ្នាកែលំអរដ្ឋបាលសាធារណៈឱ្យប្រកបដោយវិជ្ជាជីវៈ និងមានការលើកទឹកចិត្ត ។

ជាការបញ្ចប់សុន្ទរកថាគន្លឹះ សម្តេចនាយករដ្ឋមន្ត្រីបានគូសបញ្ជាក់ថា «កំណែទម្រង់មិនមែនគ្រាន់តែជាពាក្យនិយាយឱ្យរួចពីមាត់នោះឡើយ ។ ការអនុវត្តន៍កំណែទម្រង់មិនមែនតម្រូវឱ្យមានត្រឹមតែឆន្ទៈ

នយោបាយប៉ុណ្ណោះទេ ប៉ុន្តែក៏តម្រូវឱ្យមានធនធានមនុស្ស និងធនធានហិរញ្ញវត្ថុដ៏ច្រើនផងដែរ ។ ផ្លូវនៅខាងមុខមានសភាពកាន់តែច្បាស់ខ្លាំងឡើង ប៉ុន្តែនៅតែវែងឆ្ងាយ និងលំបាកលំបិន ហើយសាមគ្គីភាពរបស់សហគមន៍អន្តរជាតិ ជាមួយសេចក្តីប្រាថ្នារបស់ប្រជាជនកម្ពុជា នៅតែបន្តមានតួនាទីស្លាប់រស់នៅលើមាគ៌ានេះ» ។

វេទិកាបានសំដែងការស្វាគមន៍ចំពោះវឌ្ឍនភាពក្នុងការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលស្តែងតាមរយៈការសម្រេចបាននូវកំណើនសេដ្ឋកិច្ចយ៉ាងខ្ពស់ក្នុងឆ្នាំ២០០៦ ។ លទ្ធផលវិជ្ជមានដែលបានមកពីការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចយ៉ាងប្រយ័ត្នប្រយែង នឹងជាមូលដ្ឋានសម្រាប់រាជរដ្ឋាភិបាល រៀបចំ និងអនុវត្តនូវគោលនយោបាយដើម្បីបន្តនូវវឌ្ឍនភាពបន្តទៀត ។

រាជរដ្ឋាភិបាលបានគូសបញ្ជាក់ពីសារៈសំខាន់នៃវិស័យកសិកម្ម និងធនធានធម្មជាតិនៅក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងបានរាយការណ៍ពីវឌ្ឍនភាពក្នុងការរៀបចំនូវក្របខ័ណ្ឌគោលនយោបាយ និងគតិយុត្តិសម្រាប់គ្រប់គ្រងការប្រើប្រាស់ធនធានទាំងនេះ ដើម្បីធានាអោយមានការប្រើប្រាស់ប្រកបដោយយុទ្ធសាស្ត្រមិនប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជនមូលដ្ឋាន និងជាកត្តាបង្កើតការងារ ។ អំពីការគ្រប់គ្រងធនធានព្រៃឈើ រាជរដ្ឋាភិបាលបានគូសបញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តបង្ក្រាបការទន្ទ្រាន និងបំផ្លាញព្រៃឈើ ជាក់ស្តែងតាមរយៈការលុបចោលនូវសម្បទានដីសេដ្ឋកិច្ចក្នុងរយៈពេលថ្មីៗកន្លងមក ការរឹបអូសយកមកវិញនូវដីព្រៃដែលខុសច្បាប់ និងការបង្ក្រាបបទល្មើសព្រៃឈើ ។ រាជរដ្ឋាភិបាលបានអះអាងអំពីការប្រើប្រាស់ធនធានព្រៃឈើដោយសហគមន៍មូលដ្ឋាន ដែលនេះត្រូវបានធានា និងការពារដោយច្បាប់ស្តីពីព្រៃឈើ ។

រាជរដ្ឋាភិបាលក៏បានធ្វើការអះអាងផងដែរថា គោលដៅចម្បងនៃការផ្តល់ដីសម្បទានសេដ្ឋកិច្ច គឺជំរុញការអភិវឌ្ឍន៍វិស័យកសិកម្ម និងជំរុញវិនិយោគពីវិស័យឯកជន ។ ដៃគូអភិវឌ្ឍន៍បានកត់សំគាល់ពីទំនាក់ទំនងដ៏សំខាន់ រវាងការគ្រប់គ្រងធនធានធម្មជាតិ និងការកែលំអអភិបាលកិច្ច ដោយបញ្ជាក់ថា «ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយសមធមិ និងនិរន្តរភាពជាកត្តាចម្បងមួយ សំដៅចូលរួមកាត់បន្ថយភាពក្រីក្រ» ។ សិទ្ធិរបស់សហគមន៍ជនជាតិភាគតិចក្នុងការទទួលបាននិងការប្រើប្រាស់ដីធ្លី ក៏ត្រូវបានទទួលការយកចិត្តទុកដាក់ផងដែរ ដោយសង្កត់ធ្ងន់ពី «ភាពចាំបាច់ក្នុងការធានាអោយបាននូវតុល្យភាពរវាងការអភិវឌ្ឍន៍ជាតិ និងសិទ្ធិក្នុងការប្រើប្រាស់ដីធ្លី» ។

រាជរដ្ឋាភិបាល និងសហគមន៍ដៃគូអភិវឌ្ឍន៍បានទទួលស្គាល់ថា «ការធានាអោយមាននូវតុល្យភាពរវាងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងការប្រើប្រាស់ធនធានធម្មជាតិ ជាបញ្ហាប្រឈមដែលមានភាពស្មុគ្រ

ស្វាញ»  ។  ដោយបានគាំទ្រដល់ទស្សនាទានរបស់រាជរដ្ឋាភិបាលដែលបានលើកឡើងពាក់ព័ន្ធនឹងវិស័យកសិកម្ម ការគ្រប់គ្រងដីធ្លី ធនធានទឹក និងបញ្ហាជលផល ដៃគូអភិវឌ្ឍន៍បានទទូចស្នើសុំឱ្យរាជរដ្ឋាភិបាលបង្កើននូវកិច្ចប្រឹងប្រែងជាបន្តទៀត និងបានគូសបញ្ជាក់ពីការគាំទ្ររបស់ខ្លួនដល់កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ។

នៅក្នុងកិច្ចពិភាក្សាស្តីពីការអភិវឌ្ឍន៍ធនធានមនុស្ស ទាំងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ស្វាគមន៍នូវលទ្ធផលជាវិជ្ជមាននៃអង្កេតសុខភាពប្រជាសាស្ត្រដែលបានធ្វើនាពេលថ្មីៗកន្លងមក ដែលបង្ហាញពីការធ្លាក់ចុះនៃអត្រាស្លាប់របស់កុមារ  និងទារក  ។  លទ្ធផលក៏បានបង្ហាញពីការរីកចំរើនផងដែរ  ក្នុងការផ្តល់សេវាសុខភាពនិងការសម្រាលដល់មាតា និងទារក ក៏ដូចជាការធ្លាក់ចុះនៃអត្រាឆ្លងមេរោគអេដស៍ ។ ប៉ុន្តែអត្រាមរណៈរបស់មាតាដែលនៅមានកម្រិតខ្ពស់ នៅតែជាបញ្ហាប្រឈមនៅឡើយ ។ រាជរដ្ឋាភិបាល បានគូសបញ្ជាក់ថា  «មរណភាពរបស់មាតា  និងទារកមិនត្រឹមតែជាសោកនាដកម្មសម្រាប់តែបុគ្គលគ្រួសារនិងសហមន៍នោះទេ  ប៉ុន្តែជាសោកនាដកម្មសម្រាប់សង្គមជាតិទាំងមូល»  ។  ការប្រកាសនាពេលថ្មីៗ  នូវយុទ្ធសាស្ត្រសុខភាពផ្លូវភេទនិងបន្តពូជ គឺជាមូលដ្ឋានសំខាន់មួយសម្រាប់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ទាំងអស់ឆ្លើយតបទៅនឹងបញ្ហាទាំងនេះ ។ រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍បានឯកភាពផងដែរថា ចាំបាច់ត្រូវបន្តសម្រេចអោយបាននូវវឌ្ឍនភាពបន្តទៀតក្នុងការកាត់បន្ថយអត្រាឆ្លងមេរោគអេដស៍   ការផ្តល់ការព្យាបាលនិងគាំពារ ការយកចិត្តទុកដាក់ដល់បញ្ហាទឹកស្អាតនិងអនាម័យជាពិសេសនៅតាមជនបទ ការកាត់បន្ថយអត្រាបោះបង់ការសិក្សា និងត្រួតថ្នាក់របស់កុមារ ជាពិសេសកុមារដែលងាយរងគ្រោះ និងបន្តបញ្រ្ជាបបញ្ហាយេនឌ័រ ។

ពាក់ព័ន្ធនឹងអភិបាលកិច្ច វេទិកាបានព្រមព្រៀងគ្នាថា រាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពជាច្រើនដូចជាការអនុមតិក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមនីតិវិធីរដ្ឋប្បវេណី ។ ទន្ទឹមនឹងវឌ្ឍនភាព ត្រូវបន្តកិច្ចប្រឹងប្រែងថែមទៀត ពិសេស ការអនុមតិអោយបានឆាប់រហ័សនូវច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ និងច្បាប់គ្រឹះនានា ដើម្បីជម្រុញឱ្យមានការទទួលបាននូវយុត្តិធម៌ ។ វឌ្ឍនភាពនៅមានកម្រិតនៅឡើយ ក្នុងការដ្ឋានកំណែទម្រង់ស្នូលមួយចំនួន  ដូចជាកំណែទម្រង់រដ្ឋបាលសាធារណៈ  ដែលពាក់ព័ន្ធនឹងបញ្ហានេះរាជរដ្ឋាភិបាល  និងដៃគូអភិវឌ្ឍន៍បានឯកភាពនឹងបន្តកិច្ចពិភាក្សាបន្ថែមទៀត  ទាំងនៅកម្រិតបច្ចេកទេសនិងនយោបាយ។

កិច្ចពិភាក្សានៅក្នុងថ្ងៃទី២នៃវេទិកា  ផ្តោតទៅលើហិរញ្ញប្បទានសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងវិធានការលើកកំពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ ដោយមានការ

ឯកភាពលើសូចនាករសម្រាប់តាមដានវឌ្ឍនភាពរួមគ្នា ។ សកម្មភាពជាអាទិភាពសម្រាប់ពង្រឹងស្ថាប័ន និងពន្លឿនល្បឿនកំណែទម្រង់ សម្រាប់ឆ្នាំ២០០៧ ត្រូវបានឯកភាពតាមរយៈ«សូចនាករសម្រាប់តាមដានរួមគ្នា» ចំនួន២០ ។ សូចនាករសម្រាប់តាមដានរួមគ្នាទាំងនេះ គ្របដណ្តប់សកម្មភាពនានាដែលចាំបាច់ ដើម្បីគាំទ្រការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដូចជាអនាម័យនិងទឹកស្អាត កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អភិបាលកិច្ច សុខាភិបាល និងការអប់រំ និងហេដ្ឋារចនាសម្ព័ន្ធ ។

នៅក្នុងបទបង្ហាញពីលទ្ធផលដែលមាន នៅក្នុងរបាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា រាជរដ្ឋាភិបាលបានកត់សំគាល់ថា បើទោះជាហិរញ្ញប្បទានសហប្រតិបត្តិការ ជាមធ្យោបាយដ៏សំខាន់សំរាប់គាំទ្រការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ការគាំទ្រដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍ជាទូទៅមានសភាពបែកខ្ញែក ពុំសូវមានសង្គតិភាព និងហាក់មិនទាន់បានជួយកសាងសមត្ថភាពជាតិ ។ ការសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការគឺជា «គោលនយោបាយដែលត្រូវចាំបាច់អនុវត្ត» ព្រោះការប្រតិបត្តិកន្លងមក បានដាក់បន្ទុកមិនសមស្របមកលើស្ថាប័នរាជរដ្ឋាភិបាល និងជាហេតុធ្វើអោយមានការលំបាកដល់ការវាយតម្លៃពីឥទ្ធិពលរបស់ហិរញ្ញប្បទានសហប្រតិបត្តិការ ក្នុងការគាំទ្រអាទិភាពជាតិ ។ ដោយយល់ស្របថា របាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា«បានផ្តល់នូវភស្តុតាងមិនអាចប្រកែកបានពីភាពបែកខ្ញែកនៃហិរញ្ញប្បទានសហប្រតិបត្តិការ» តំណាងសហគមន៍ដៃគូអភិវឌ្ឍន៍ បានសំដែងការស្វាគមន៍ និងគាំទ្រដល់ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៅតាមវិស័យ សំដៅធានាអោយបាននូវ«បំណែងចែកពលកម្ម» ដែលប្រសើរជាងនេះ ក្នុងចំណោមដៃគូអភិវឌ្ឍន៍ កាត់បន្ថយនូវការផ្តល់ការគាំទ្រប្រកបដោយភាពបែកខ្ញែក និងជំរុញឱ្យមានការប្រកាន់យកថែមទៀត នូវអភិក្រមគ្រប់គ្រងទូទាំងវិស័យស្របតាមស្ថានភាពជាក់ស្តែងនៅតាមវិស័យ ។

ដោយគូសបញ្ជាក់ពីការរួមចំណែករបស់សហគមន៍អន្តរជាតិ ក្នុងការផ្តល់ហិរញ្ញប្បទាន «ប្រកបដោយចីរភាព» សម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិក្នុងរយៈពេលមធ្យម ឯកឧត្តមទេសរដ្ឋមន្ត្រី **គាត ឈន់** បានគូសបញ្ជាក់ថា រាជរដ្ឋាភិបាលនឹងមិនស្នើសុំឱ្យដៃគូអភិវឌ្ឍន៍ធ្វើការប្រកាស«សន្យា»ផ្តល់ហិរញ្ញប្បទាន ដូចបានធ្វើដូចសព្វមួយដងទៀតឡើយ។ ប៉ុន្តែរាជរដ្ឋាភិបាល ស្នើសុំឱ្យដៃគូអភិវឌ្ឍន៍ផ្តល់នូវតួលេខប៉ាន់ស្មានសម្រាប់ចង្អុលបង្ហាញពីការផ្តល់ហិរញ្ញប្បទានគាំទ្រសម្រាប់រយៈពេល ៣ ឆ្នាំខាងមុខ ។ បន្ទាប់មក ដៃគូអភិវឌ្ឍន៍បានធ្វើសេចក្តីថ្លែងការណ៍ពីទំហំនៃការគាំទ្រ ជាមួយនឹងការរំពឹងថា នឹងមានការជឿនលឿនបន្ថែមទៀតនៅតាមការដ្ឋានកំណែទម្រង់ទាំងឡាយ។ យោងតាមសេចក្តីប្រកាសរបស់ឯកឧត្តម

ទេសរដ្ឋមន្ត្រីប្រធានវេទិកា ការគាំទ្រហិរញ្ញប្បទានសរុបសម្រាប់ឆ្នាំ២០០៧ មានប្រមាណជាង ៦៨៩ លានដុល្លាសហរដ្ឋអាមេរិក ។ តួលេខនេះ រួមបញ្ចូលជាលើកដំបូង តួលេខដែលផ្តល់ដោយសាធារណរដ្ឋប្រជាមានិតចិន ។ សម្រាប់ឆ្នាំ២០០៨ និង២០០៩ ខាងមុខ ហិរញ្ញប្បទានសហប្រតិបត្តិការ នឹងមានកម្រិតប្រហាក់ប្រហែលឆ្នាំ ២០០៧ ។

ឯកឧត្តមទេសរដ្ឋមន្ត្រីប្រធានវេទិកាបានថ្លែងអំណរគុណចំពោះការគាំទ្រទាំងនេះ និងគូសបញ្ជាក់ថា «ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនឹងទទួលបាននូវហិរញ្ញប្បទានសមស្រប យ៉ាងហោចណាស់រហូតដល់ដំណាច់ឆ្នាំ២០០៩»។ វេទិកាទាំងមូលបានឯកភាពថាបញ្ហាប្រឈមរបស់កម្ពុជាគឺការបន្តពង្រឹង និងធ្វើឱ្យកាន់តែស៊ីជម្រៅថែមទៀត នូវកំណែទម្រង់នានា សំដៅអភិវឌ្ឍសង្គម និងកែលំអអភិបាលកិច្ច ។

រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍បានឯកភាព គ្រោងនឹងរៀបចំវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា លើកទី២ នាខែធ្នូ ឆ្នាំ ២០០៨ខាងមុខ ។

**************

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងតាមអាសយដ្ឋានអ៊ីម៉ែលៈ cdcf@crdb.gov.kh ឬគេហទំព័រ www.cdc-crdb.gov.kh ។